# CCHR គ្រោងបើកកម្មវិធីប្រកួតស្នាដៃតែងនិពន្ធពីវីរភាពលោកបណ្ឌិត កែម ឡី ក្នុងឱកាសរំលឹកខួបមរណភាពគម្រប់៧ឆ្នាំ

ភ្នំពេញ៖ ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣ ខាងមុខនេះគឺជាថ្ងៃខួបគម្រប់៧ឆ្នាំនៃមរណភាពរបស់លោកបណ្ឌិត កែម ឡី ដែលជាអ្នកវិភាគនយោបាយ និងជាអ្នកតស៊ូមតិដើម្បីលទ្ធិប្រជាធិបតេយ្យនិងសិទ្ធិមនុស្សដ៏លេចធ្លោមួយរូប។

ជារៀងរាល់ឆ្នាំចាប់តាំងពីលោកបណ្ឌិត កែម ឡី ទទួលមរណភាពដោយសារឃាតករបាញ់សម្លាប់គឺនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៦ នោះមក មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) ក៏ដូចជាក្រុមយុវជនមួយចំនួនតែងតែចូលរួមរំលឹកខួបនៃមរណភាពរបស់លោកបណ្ឌិតជារៀងរាល់ឆ្នាំ។
ដោយឡែកនៅក្នុងឆ្នាំនេះ CCHR នឹងរៀបចំ ព្រឹត្តិការណ៍មួយចំនួននៅក្នុងខែកក្កដានេះ ដើម្បីជាការចូលរួម រម្លឹកខួបគម្រប់ ៧ ឆ្នាំនៃមរណភាពលោកបណ្ឌិត កែម ឡី ផងដែរ។

CCHR បញ្ជាក់ពីកាលបរិច្ឆេទនៃកម្មវិធីនីមួយៗរួមមាន នៅថ្ងៃទី១៦ ខែមិថុនា ដល់ថ្ងៃទី០១ ខែកក្កដា CCHRប្រកាសជ្រើសរើសអ្នកដែលមានសមត្ថភាពឱ្យចូលរួមប្រកួត ប្រជែងនិពន្ធ ឬតែងកំណាព្យបង្ហាញអំពីការនឹករឭកដល់លោកបណ្ឌិត កែម ឡី។ ចំណែកនៅថ្ងៃទី០១ ដល់ថ្ងៃទី៣១ ខែកក្កដា CCHR នឹងប្តូរគម្របទំព័រហ្វេសប៊ុករបស់ខ្លួនបច្ចុប្បន្នដោយដាក់តាំងបង្ហាញរូបភាពលោកបណ្ឌិត កែម ឡី ជំនួសវិញ។ បន្ថែមពីនេះ ចាប់ពីថ្ងៃទី០៣ ដល់ថ្ងៃទី០៩ ខែកក្កដា CCHR នឹងបង្ហោះសម្រង់សម្តីរបស់លោក បណ្ឌិត កែម ឡី នៅលើទំព័រហ្វេសប៊ុករបស់ខ្លួន។

សម្រាប់ថ្ងៃទី០៦ ខែកក្កដា CCHRនឹងរៀបចំពិធីបង្សុកូល ឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធលោកបណ្ឌិត កែម ឡី នៅការិយាល័យរបស់CCHRផ្ទាល់។ និងជាកម្មវិធីចុងក្រោយ CCHR មានរៀបចំកម្មវិធីវិទ្យុពិភាក្សាលើប្រធានបទទាក់ទង នឹងយុទ្ធនាការ និងការនឹករឭកដល់លោកបណ្ឌិត កែម ឡី ព្រមទាំងមានការបង្ហោះវីដេអូ ស្តីពីដំណើររឿងខ្លីមួយមានចំណងជើងថា «ពាក្យពិត» នៅលើទំព័រហ្វេសប៊ុករបស់ខ្លួននៅថ្ងៃទី០៧ ខែកក្កដាផងដែរ៕

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# សេចក្តីប្រកាសព័ត៌មាន
## មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាប្រារព្ធខួបគម្រប់ប្រាំពីរឆ្នាំនៃមរណភាព
## លោកបណ្ឌិត កែម ឡី

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៣

ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣ គឺជាថ្ងៃខួបគម្រប់៧ឆ្នាំនៃមរណភាពរបស់លោកបណ្ឌិត កែម ឡី ជាអ្នកវិភាគនយោបាយ និងជាអ្នកតស៊ូមតិដើម្បីលទ្ធិប្រជាធិបតេយ្យនិងសិទ្ធិមនុស្សដ៏លេចធ្លោមួយរូប។ លោកបណ្ឌិត កែម ឡី ត្រូវបានឃាតករបាញ់សម្លាប់ទាំងព្រឹកនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៦ នៅស្ថានីយប្រេងឥន្ធនៈមួយកន្លែងក្នុងរាជធានីភ្នំពេញ។

ក្នុងឱកាសរម្លឹកខួបគម្រប់៧ឆ្នាំនៃមរណភាពលោកបណ្ឌិត កែម ឡី នេះ ម.ស.ម.ក នឹងរៀបចំព្រឹត្តិការណ៍មួយចំនួននៅក្នុងខែកក្កដា ដូចខាងក្រោម៖

១. ចាប់ពីថ្ងៃទី១៦ ខែមិថុនា ដល់ថ្ងៃទី០១ ខែកក្កដា សាធារណជនអាចចូលរួមប្រកួតប្រជែងនិពន្ធ ឬតែងកំណាព្យបង្ហាញអំពីការនឹករឭកដល់លោកបណ្ឌិត កែម ឡី។

២. ចាប់ពីថ្ងៃទី០១ ដល់ថ្ងៃទី៣១ ខែកក្កដា ម.ស.ម.ក នឹងប្តូរគម្របទំព័រហ្វេសប៊ុករបស់ខ្លួនបច្ចុប្បន្ន ដោយដាក់តាំងបង្ហាញរូបភាពលោកបណ្ឌិត កែម ឡី ជំនួសវិញ។

៣. ចាប់ពីថ្ងៃទី០៣ ដល់ថ្ងៃទី០៩ ខែកក្កដា ម.ស.ម.ក នឹងបង្ហោះសម្រង់សម្តីរបស់លោកបណ្ឌិត កែម ឡី នៅលើទំព័រហ្វេសប៊ុករបស់ ម.ស.ម.ក។

៤. នៅថ្ងៃទី០៦ ខែកក្កដា ម.ស.ម.ក នឹងរៀបចំពិធីបុណ្យទក្ខិណានុប្បទាន និងពិធីបង្សុកូលឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធលោកបណ្ឌិត កែម ឡី នៅការិយាល័យរបស់ ម.ស.ម.ក។

៥. នៅថ្ងៃទី០៧ ខែកក្កដា ម.ស.ម.ក នឹងរៀបចំកម្មវិធីវិទ្យុពិភាក្សាលើប្រធានបទទាក់ទងនឹងយុទ្ធនាការ និងការនឹករឭកដល់លោកបណ្ឌិត កែម ឡី ព្រមទាំងមានការបង្ហោះវីដេអូស្តីពីដំណើររឿងខ្លីមួយមានចំណងជើងថា «**ពាក្យពិត**» នៅលើទំព័រហ្វេសប៊ុករបស់ ម.ស.ម.ក ។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង លោក សួន យុធ្យា នាយកផ្នែកតស៊ូមតិ ម.ស.ម.ក តាមអ៊ីម៉ែល:** yuthyia@cchrcambodia.org **ឬ ទូរស័ព្ទ: +៨៥៥ (០) ៨៨ ៨១៤ ២៧៨៣៕**